ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការព្រហ្មទណ្ឌ

**សំណុំរឿងព្រហ្មទណ្ឌលេខ ២២០៧ អក**

ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣

**សំណុំរឿងស៊ើបសួរលេខ ១៤២១ ស.ស**

ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣

**សំណុំរឿងជំនុំជម្រះលេខ ២៤៨ ជ.រ**

ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤

**សាលក្រមព្រហ្មទណ្ឌលេខ ០២៧/ក**

ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការ | ៖ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ៥ ម៉ោង ១០ ព្រឹក។ |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ១ ម៉ោង ១០ ព្រឹក។ |

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

**ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាលនិងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

១. ឈ្មោះ [redacted] វិសាល ភេទប្រុស កើតឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរសិស្ស។

ទីកន្លែងកំណើតនៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។

ទីលំនៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] ស៊ីម (រ) ម្ដាយឈ្មោះ [redacted] ភារី (រ) នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៩ថ្មី

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ (ក្នុងឃុំ)

កាលបរិច្ឆេទនៃការឃាត់ខ្លួន ៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។



Scanned with CamScanner

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។

២. ឈ្មោះ [redacted] សាន់ ភេទប្រុស កើតថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៨ ថ្ងៃ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ។

ទីកំណើតនៅភូមិ[redacted] ខេត្តកណ្តាល។

ទីលំនៅភូមិ[redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ[redacted] លី (រស់) ម្តាយឈ្មោះ[redacted] ម៉ើសុំ (រស់) នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី៦ ថ្មី។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

លោក [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ផ្ទះលេខ VA-៥៤០ ផ្លូវវិមានអាហារ(ជ្រោយចង្វារ) សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

លោក [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ផ្ទះលេខបេ ៥ ផ្លូវលេខ ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

លោកស្រី [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

៣. ឈ្មោះ[redacted] ហុងស្រេង ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ១ ថ្ងៃ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ។

ទីកន្លែងកំណើតនៅភូ[redacted] ខេត្តតាកែវ។

ទីលំនៅភូមិតាឧទ ឃុំម្លូង ស្រុកបាទី ខេត្តតាកែវ។

ឪពុកឈ្មោះ [redacted] ស្រ៊ាង (រស់) ម្តាយឈ្មោះ[redacted] គង្គារ (រស់) នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី១០ថ្មី

ប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន។

កាលបរិច្ឆេទនៃការឃាត់ខ្លួន ៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។



Scanned with CamScanner

ការិយាល័យ៖ផ្ទះលេខ១៨E ផ្លូវជាតិលេខ ២ ភូមិដើមមៀន សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

លោកស្រី [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**៤.** ឈ្មោះ [redacted] **គុយហេង** ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៣ ថ្ងៃ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ សិស្ស។

ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តតាកែវ។

ទីលំនៅភូមិ [redacted] ខេត្តតាកែវ។

ឪពុកឈ្មោះ [redacted] **ដាណារី** (រស់) ម្តាយឈ្មោះ [redacted] **គីមយាង** (រស់) នៅលើវ កម្រិតវប្បធម៌ថ្នាក់ទី១២ថ្មី

ប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន។ (ក្នុងឃុំ)

កាលបរិច្ឆេទនៃការឃាត់ខ្លួន ៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ផ្ទះលេខ២៦ ផ្លូវបុរី ២ កែងបុរី ៣ (បុរីប៉េងហួតភូមិន្ទ ផ្លូវលេខ ៥៩៨) ភូមិទំនប់ សង្កាត់ភ្នំពេញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

លោកស្រី [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**៥.** ឈ្មោះ [redacted] **រក្សា ហៅ អឺ** ភេទប្រុស កើតថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ ៦ ខែ ១ ថ្ងៃ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ។

ទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្តាល។

ទីលំនៅភូមិប្រធាតុ(ក) សង្កាត់ព្រែកថ្មី ក្រុងសំពៅលូន ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted] **ភូ** (រស់) ម្តាយឈ្មោះ [redacted] **ធឿន** (រស់) នៅលើវ កម្រិតវប្បធម៌ថ្នាក់ទី០៤ថ្មី

ប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន។ (ក្នុងឃុំ)

កាលបរិច្ឆេទនៃការឃាត់ខ្លួន ៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោកស្រី [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។



Scanned with CamScanner

៦. ឈ្មោះ [redacted] ឈាន ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ។

ទីកន្លែងកំណើតនៅ[redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិពោធិរាម្នា ឃុំព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] សាន (ស្លាប់) ម្ដាយឈ្មោះ [redacted] ភាព (រស់) នៅឡើយ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោកស្រី [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ត្រូវជាប់ចោទពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ (ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៧. ឈ្មោះ [redacted] គីមហុង ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរ នៅផ្ទះ។

ទីកន្លែងកំណើតនៅ[redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិអន្លង់[redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] ចាន់ (រស់) ម្ដាយឈ្មោះ [redacted] វណ្ណៈ (រស់) នៅឡើយ កម្រិតវប្បធម៌ថ្នាក់ទី០៩ថ្មី

ប្រវត្តិផ្ដន្ទាទោសដោយតុលាការពីមុន គ្មាន។ (ក្នុងឃុំ)

កាលបរិច្ឆេទនៃការឃាត់ខ្លួន ៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។

ត្រូវជាប់ចោទពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោកស្រី [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**សំណុំរឿងព្រហ្មទណ្ឌនេះបញ្ជូនមកជំនុំជម្រះតាម ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៣២ ដក ដស ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ដែលមាន៖**

**អង្គហេតុដែលប្ដឹងមកតុលាការ**



Scanned with CamScanner

កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២០ និង ៣០នាទី កើតករណី **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ស្ថិតនៅភូមិព្រែកបី ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល ដែលបង្កឡើងដោយឈ្មោះ [redacted] សាន់ ភេទប្រុស អាយុ ១៧ ឆ្នាំ ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៥ ឆ្នាំ ឈ្មោះ [redacted] គុយហេង ភេទប្រុស អាយុ ១៧ឆ្នាំ ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស អាយុ ១៧ ឆ្នាំ ឈ្មោះ [redacted] វត្ថា ហៅ ធី ភេទប្រុស អាយុ ១៦ ឆ្នាំ ឈ្មោះ [redacted] គីមហុង ភេទប្រុស អាយុ ១៦ឆ្នាំ ឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ ១៦ឆ្នាំ និងបក្ខពួក បាននាំគ្នាយកកាំបិតផ្គាក់ ដាវ និងដុំថ្ម ទៅវ៉ៃ និងគប់លើជនរងគ្រោះឈ្មោះ [redacted] ម៉េងហ៊ិន ភេទប្រុស អាយុ ១៦ ឆ្នាំ និងបក្ខពួក ដែលកំពុងអង្គុយផឹកកាហ្វេនៅផ្ទះឈ្មោះ ម៉េង ឃើញដូចនោះជនរងគ្រោះ និងបក្ខពួកបាននាំគ្នារត់ចូលផ្ទះប្រជាពលរដ្ឋនៅក្បែរនោះ ក្រោយមកជនសង្ស័យបានរត់គេចខ្លួនអស់ទៅ។ លុះនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ជនរងគ្រោះបានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលកោះធំ(ខ) ក្រោយមកកម្លាំងសមត្ថកិច្ចនគរបាលជំនាញស្រុកកោះធំ បានសហការណ៍ជាមួយប៉ុស្តិ៍កោះធំ(ខ) ស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យចំនួន ០៦ នាក់ ចំណែកឈ្មោះ [redacted] ណារិន និងអ្នកផ្សេងទៀតបានរត់គេចខ្លួនបានអស់។ តាមកំណត់ហេតុធ្វើតេស្តទឹកនោមរបស់ឈ្មោះ [redacted] គីមហុង គឺមានផ្ទុកនូវសារធាតុញៀន(+)។

## អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

### ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្តី

អំពីវិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

### ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

#### ១. ការសួរចម្លើយជនជាប់ចោទ

១.១. ឈ្មោះ [redacted] វិសាល ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៧ និង ៣០ នាទី ខ្លួនរួមនិងបក្ខពួកចំនួន០៧នាក់មានដូចជា ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៥ ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាលជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខជិះពីក្រោយ ឈ្មោះ [redacted] គុយហេង ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិជំនីក ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ ជាអ្នកបើកបរម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅ មិនចាំផ្លាក លេខ ឈ្មោះ [redacted] សាន់ ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ កែឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខជាអ្នកបើកបរ។ ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិតានន ឃុំដូង ស្រុកបាទី ខេត្តកណ្តាល ជាអ្នកជិះនៅពីក្រោយម៉ូតូម៉ាកហុងដាឌ្រីម សេរីឆ្នាំ២០២១ កែឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខ និងជាអ្នកកាន់កាំបិតផ្គាក់។ ឈ្មោះ [redacted] គីមហុង ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិអន្លង់តាសេកលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់កាំបិតផ្គាក់។ ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ រស់នៅភូមិកំពង់ស្វាយ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល

ជាអ្នកជិះម៉ូតូមុងដាទ្រីម សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកបើកម៉ូតូ ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៨ ឆ្នាំ រស់នៅភូមិកញ្ជើល ឃុំកំពង់រាប ស្រុកព្រែកប្បាស ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាទ្រីម សេរីឆ្នាំ២០២២ ពណ៌ស មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់ដាវ។ លុះពេលខ្លួនបានត្រលប់មកពីមើលកុននៅបុណ្យកឋិនវិញមក នៅវេលាម៉ោង ២១ និង ៣០ នាទី ថ្ងៃខែឆ្នាំ ដដែល នៅពេលជិះដល់ចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល ស្រាប់តែពួកខ្លួនបានជួបនិងក្រុមពួកក្មេងទំនើងដែលធ្លាប់មានទំនាស់ជាមួយពួកខ្លួនកាលពីមុន ពួកខ្លួនក៏នាំគ្នាយកដេញកាប់ដេញវាយក្រុមក្មេងទំនើងទាំងអស់តែម្តង។ ក្រោយមកក្រុមពួកក្មេងទំនើងទាំងនោះក៏បាននាំគ្នារត់អស់ទៅ បន្ទាប់មកពួកខ្លួនក៏បាននាំគ្នាត្រឡប់មកផ្ទះវិញ រៀងៗខ្លួនទៅ។ បន្ទាប់ពីសកម្មភាពរួចហើយពួកខ្លួនក៏នាំគ្នាទៅដេកវិញរៀងៗខ្លួនអស់ទៅ។ ក្រោយមកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០នាទី ទើបសមត្ថកិច្ចនាំខ្លួនរូបខ្លួនមកសាកសួរនៅអធិការដ្ឋាននគរបាលស្រុកកោះធំតែម្តង។

**១.២. ឈ្មោះ [redacted] វិសាល** ចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២៣ ទុកជាបានការដដែល និងសូមបន្ថែមថាខ្លួន និងបក្ខពួកមានគ្នាសរុបចំនួន ០៧នាក់បានជិះម៉ូតូចំនួន ០៣គ្រឿង ដោយមានកាំបិតផ្គាក់ ១ដើម, ដាវ១ដើម, និងដុំថ្មមួយចំនួន ទៅវាយពួកព្រែកទុំ ពេលទៅដល់ម្តុំហាងកាហ្វេ ស្រាប់តែភាគីខាងនោះឃើញពួកខ្លួនក៏បានរត់គេចខ្លួនបាត់អស់ទៅ។ កន្លងមកពួកព្រែកទុំធ្លាប់បានកាប់ម៉ូតូពួកខ្លួនម្តង។ ខ្លួនសូមបញ្ជាក់បន្ថែមថាពួកខ្លួនមិនបានចុះកាប់ និងវាយជនរងគ្រោះនោះទេ មានតែបក្ខពួកមួយទៀតដែលមានគ្នា២០នាក់ទេ ដែលបានវាយជនរងគ្រោះនោះ។ ពេលសមត្ថកិច្ចឃាត់ខ្លួនមិនមានដកហូតអ្វីទេ ហើយខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀនទេ។ ខ្លួនសូមសំណូមពរឱ្យតំណាងអយ្យការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

**១.៣. ឈ្មោះ [redacted] វិសាល** ចំពោះមុខចៅក្រមស៊ើបសួរ៖ នៅក្នុងរឿងនេះ ខ្លួនសូមរក្សាចម្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ និងនៅតំណាងអយ្យការដដែល។ នៅក្នុងរឿងនេះ ខ្លួនពិតជាបានប្រព្រឹត្តដូចតំណាងអយ្យការចោទប្រកាន់មែន។ សមត្ថកិច្ចបានឃាត់ខ្លួន កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅចំណុចផ្ទះរបស់ខ្លួននៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល។ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២២ ខ្លួន និងបក្ខពួកចំនួន ០៧នាក់ បានជិះម៉ូតូចំនួន ០៣គ្រឿង ទៅដេញកាប់ជនរងគ្រោះចំនួន ០២នាក់ (មិនស្គាល់ឈ្មោះ) ប្រាកដមែន ប៉ុន្តែកាប់មិនបានឡើយ ដោយសារជនរងគ្រោះបាននាំគ្នារត់ចូលផ្ទះរបស់គេទាន់។ មូលហេតុដែល ខ្លួន និងបក្ខពួកនាំគ្នាទៅដេញកាប់ជនរងគ្រោះ ព្រោះជនរងគ្រោះធ្លាប់លកាប់ម៉ូតូ ០១ គ្រឿង របស់ឈ្មោះ [redacted] គុយហេង ម៉ាក់ ហុងដាឌ្រីម ដែលជាមិត្តភក្តិរបស់ខ្លួន។ ខ្លួនសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ហើយខ្លួនចង់ឆាប់បានចូលរៀនវិញ។

**១.៤. ឈ្មោះ លី សាន់** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ កន្លងមកនៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១៥ និង ៣០នាទី ខ្លួនហើយ និងបក្ខពួករបស់ខ្លួនដែលមានរហ័សនាមក្រុម៥២ ធ្លាប់បានធ្វើសកម្មភាពប្រើហិង្សាដេញកាប់ទៅលើក្រុមក្មេងទំនើងមួយក្រុមដែលមានរហ័សនាមPT ដែលមានទីតាំងនៅចំណុចត្នប

លក់ចាប់ហួយឈ្មោះ [redacted] ផល្លី នៅចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល ដោយគ្នាចូលរួមចំនួន ១០នាក់ ជិះម៉ូតូ ០៥គ្រឿង ដោយមានឈ្មោះដូចតទៅ ឈ្មោះ [redacted] សាន់ ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ឈ្មោះ [redacted] ភេទប្រុស អាយុ ១៩ឆ្នាំ រស់នៅសង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្ដាល ឈ្មោះ [redacted] គឹមហុង ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្ដាល ឈ្មោះ ហុង ភេទប្រុស អាយុ ១៩ឆ្នាំ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកឬស្សី ខេត្តតាកែវ។ ឈ្មោះ ហ៊្សី ភេទប្រុស អាយុ ១៩ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្ដាល។ឈ្មោះ សាល ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។ ឈ្មោះ [redacted] ណាសៀត ភេទប្រុស អាយុ ១៦ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។ ឈ្មោះ ហ៊្សី ភេទប្រុស អាយុ ១៩ឆ្នាំ រស់នៅភូមិព្រែកថ្មី ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។ ឈ្មោះ វី ភេទប្រុស អាយុ ២០ឆ្នាំ រស់នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។ ក្រោយមកនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១៩ និង ៣០នាទី ក្រុមពួកPTបានឆាតតាមហ្វេសប៊ុក និងនិយាយបបួលក្រុម៥២ពួកខ្លួនដើម្បីណាត់គ្នាទៅកាប់គ្នានៅចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដល។ លុះនៅវេលាម៉ោង ២០ និង ៣០នាទី ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួនរួមនិងបក្ខពួកក្រុម៥២ មានគ្នា ០៧នាក់ ជិះម៉ូតូប្រហែល ០៣គ្រឿង ប្រដាប់ដាវ កាំបិតផ្គាក់ ហើយកាំបិត ក្នុងម្នាក់មួយដើមក្នុងដៃបានចេញពីកន្លែងមើលកុនរឹញដែលស្ថិតនៅក្នុងវត្តអន្លង់តាសេក ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល រឹញក៏បាននាំគ្នាជិះត្រលប់មកជួបជុះគ្នាចំណុចភូមិព្រែកមិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល។ ដោយមានឈ្មោះដូចតទៅ៖ ខ្លួនផ្ទាល់ឈ្មោះ [redacted] សាន់ ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ជិះម៉ូតូសង់ ០២២ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ខ្លួនជាអ្នកបើកបរមិនមានកាន់កាំបិតទេ។ ឈ្មោះ [redacted] គុយហេង ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិជំនិក ឃុំកំពង់រាប ស្រុកព្រែកឬស្សី ខេត្តតាកែវ ជាអ្នកបើកបរម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស អាយុ ១៧ ឆ្នាំ ភូមិតានន ឃុំម្លូង ស្រុកបាទី ខេត្តតាកែវ ជាអ្នកជិះនៅពីក្រោយម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ កែឡើង ២០២២ ពណ៌ស មិនចាំផ្លាកលេខ និងជាអ្នកកាន់កាំបិតផ្គាក់។ ឈ្មោះ ស៊ន វិសាល ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជិះពីក្រោយ។ ឈ្មោះ ណាក់ ភេទប្រុស អាយុ ១៦ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកបើកម៉ូតូ។ ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកឬស្សី ខេត្តតាកែវ ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២២ ពណ៌ស មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់ដាវ។ ឈ្មោះ [redacted] គឹមហុង ភេទប្រុស ១៦ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្ដាល ជាអ្នកជិះពីក្រោយម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកកាន់កាំបិតផ្គាក់។ ក្រៅពីនេះខ្លួនមិនស្គាល់នណារទៀតនោះទេ។ បន្ទាប់ពីបានជួបជុំគ្នាអស់ហើយ នៅវេលាម៉ោង ២១ និង ៣០នាទី ថ្ងៃទី១៨ ខែ

វិច្ឆិកា ឆ្នាំ២០២៣ រូបខ្លួន និងបក្ខពួកក៏បានចេះធ្វើសកម្មភាពដោយនាំគ្នាជិះម៉ូតូដែលរៀបរាបខាងលើ ហើយក្នុងដៃម្នាក់ៗកាន់ប្រដាប់ដោយដាវ កាំបិតផ្គាក់ កាំបិតខ្មែរ ជិះនៅតាមផ្លូវជាតិលេខ២១ សំដៅទៅរកក្រុមពួកPT តែម្តង ភ្លាមៗនោះស្រាប់តែពួកខ្លួនបានឃើញក្រុមពួកPT ដែលមានគ្នាប្រហែលជាង៣០នាក់ នៅកំពង់ឈរចាំពួកខ្លួនតែម្តងដោយក្នុងដៃម្នាក់ៗកាន់សុតតែដាវ កាំបិតតាំងតោ និងកាំបិតខ្មែរ ឃើញដូចនោះខ្លួននិងបក្ខពួកក៏បានចូលទៅដេញកាប់តែម្តង ហើយពួកក្រុមPT ក៏បានកាប់តបតមកពួកក្រុមខ្លួនវិញដូចគ្នាផងដែរ។ បន្ទាប់ពីធ្វើសកម្មភាពរួចហើយគ្នាគ្នាខ្លួនឈ្មោះ ឈាន និងឈ្មោះ ហុង បានត្រូវរបួស ម្នាក់របេះចំដៃ ម្នាក់របេះជើង និងខ្ទិចម៉ូតូចំនួន ០២គ្រឿង រួចក៏នាំជិះម៉ូតូរត់ចូលផ្ទះរៀងៗខ្លួនអស់ទៅ។ ក្រោយមកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០នាទី ទើបសមត្ថកិច្ចនាំខ្លួនមកសាកសួរនៅអធិការដ្ឋាននគរបាលស្រុកកោះធំតែម្តង។

**១.៥.** ឈ្មោះ [redacted] **សាន់** ចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២៣ ទុកជាបានការដដែល និងសូមបន្ថែមថាខ្លួន និងបក្ខពួកមានគ្នាសរុបចំនួន ០៧នាក់ឈ្មោះ តុត, ហុង ,សាល, គីមហុង, គុយហេង, ណា បានជិះម៉ូតូចំនួន ០៣គ្រឿង មានកាន់ដុំថ្ម និងកាំបិតផ្គាក់ ទៅធ្វើសកម្មភាពវាយក្រុម៥២នៅព្រែកទុំ ដែលមានឈ្មោះ [redacted] **ម៉េងហ៊ិន** និងបក្ខពួក ដោយពួកខ្លួនត្រឹមតែបានគប់ដុំថ្មទៅពួកវាតែប៉ុណ្ណោះ។ ពេលកើតហេតុនោះខ្លួនជាអ្នកឌុបឈ្មោះ តុត ទៅ។ កន្លងមកខ្លួន និងបក្ខពួកបានទៅរកវាយជនរងគ្រោះបានចំនួន ០២លើកដែរ តែមិនដែលបានវាយគេទេ។ ពេលសមត្ថកិច្ចឃាត់ខ្លួន មិនបានដកហូតអ្វីទេ។ ខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀនទេ។ ខ្លួនសូមសំណូមពរឱ្យតំណាងអយ្យការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

**១.៦.** ឈ្មោះ [redacted] **សាន់** ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយនៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាលទុកជាបានការដដែល។ នៅក្នុងរឿងនេះខ្លួនពិតជាបានប្រព្រឹត្តដូចតំណាងអយ្យការចោទ ប្រកាន់មែន។ សមត្ថកិច្ចបានឃាត់ខ្លួន កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅចំណុចផ្ទះរបស់ខ្លួននៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល។ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២១ ខ្លួន និងបក្ខពួកចំនួន ០៧ នាក់ បានជិះម៉ូតូចំនួន ០៣គ្រឿង ទៅដេញកាប់ជនរងគ្រោះចំនួន ០៤ នាក់ (មិនស្គាល់ឈ្មោះ) ប្រាកដមែន ប៉ុន្តែកាប់មិនបានឡើយ ដោយសារជនរងគ្រោះបាននាំគ្នារត់ចូលផ្ទះរបស់គេទាន់។ សូមបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនមិនបានចុះទៅដេញកាប់ ឬ គប់ជនរងគ្រោះទេ ដោយខ្លួនជាអ្នកបើកម៉ូតូឌុបឈ្មោះ **រី ហុងស្រេង ហៅ តុត** ហើយឈ្មោះនេះបានកាន់ដុំថ្មចំនួន ០១ដុំ ចំណែកដាវ ចំនួន ០១ដើម របស់ឈ្មោះ **ចាន់ គីមហុង** និងកាំបិតផ្គាក់ ឈ្មោះ **ហុង** (គេចខ្លួន)។ មូលហេតុដែល ខ្លួន ទៅដេញកាប់ជនរងគ្រោះ ព្រោះឈ្មោះ **រី** ភេទប្រុស ទីលំនៅបច្ចុប្បន្នរស់នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ឈ្មោះ **យ៉ត** ភេទប្រុស ទីលំនៅបច្ចុប្បន្នរស់នៅភូមិព្រែកបិ, ឈ្មោះ ហៀក ភេទប្រុស ធ្លាប់មានទំនាស់ជាមួយខ្លួនតាមរយ: Messenger ព្រមទាំងធ្លាប់មកគប់ដំបូលផ្ទះរបស់ខ្លួនទៀតផង។ សូមបញ្ជាក់ថា ខ្លួនបានទៅដេញកាប់គេនេះទើបតែជាលើកទី ០១ ទេ។ ចំណែកការប្រើប្រាស់គ្រឿងញៀន គឺខ្លួនមិនចេះប្រើប្រាស់ឡើយ។ ខ្លួនសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យ



Scanned with CamScanner

ខ្លួនផង ហើយខ្លួនចង់ឆាប់បានទៅផ្ទះវិញ ព្រោះឪពុកម្ដាយរបស់ខ្លួនឈឺ។

១.៧. ឈ្មោះ [redacted]**គីមហេង** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៧ និង ៣០នាទី ខ្លួនរួម និងបក្ខពួកចំនួន ០៧នាក់មានដូចជា ខ្លួនផ្ទាល់ជាអ្នកបើកបរម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅ មិនចាំផ្លាកលេខ។ ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៥ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១២ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជិះពីក្រោយ។ ឈ្មោះ [redacted] **សាន់** ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ ដៃឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខជាអ្នកបើកម៉ូតូ។ ឈ្មោះ [redacted] **ហុងស្រេង** ភេទប្រុស អាយុ ១៧ឆ្នាំ ភូមិតានន ឃុំដូង ស្រុកបាទី ខេត្តតាកែវ ជាអ្នកជិះនៅពីក្រោយម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ កែឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខ និងជាអ្នកកាន់កាំបិតផ្គាក់។ ឈ្មោះ [redacted] **គីមហុង** ភេទប្រុស ១៦ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្ដាល ជាអ្នកជិះពីក្រោយម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកកាន់កាំបិតផ្គាក់។ ឈ្មោះ **ណាក់** ភេទប្រុស ១៦ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកបើកម៉ូតូ។ ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២២ ពណ៌ស មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់ដាវ។ លុះពេលខ្លួនបានត្រលប់មកពីមើលកុននៅបុណ្យកឋិនវិញមកនៅវេលាម៉ោង ២១ និង ៣០នាទី ថ្ងៃខែឆ្នាំដដែល នៅពេលជិះដល់ចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល ស្រាប់តែពួកខ្លួនបានជួបនិងក្រុមពួកក្មេងទំនើងដែលធ្លាប់មានទំនាស់ជាមួយពួកខ្លួនកាលពីមុន ពួកខ្លួនក៏នាំគ្នាយកដេញកាប់ដេញវាយក្រុមក្មេងទំនើងទាំងអស់តែម្ដង។ ក្រោយមកក្រុមពួកក្មេងទំនើងទាំងនោះក៏បាននាំគ្នារត់អស់ទៅ បន្ទាប់មកពួកខ្លួនក៏បាននាំគ្នាត្រឡប់មកផ្ទះវិញរៀងៗខ្លួនទៅ។ បន្ទាប់ពីសកម្មភាពរួចហើយពួកខ្លួនក៏នាំគ្នាទៅដេកវិញរៀងៗខ្លួនអស់ទៅ។ ក្រោយមកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០នាទី ទើបសមត្ថកិច្ចនាំខ្លួនរូបខ្លួនមកសាកសួរនៅអធិការដ្ឋាននគរបាលស្រុកកោះធំតែម្ដង។

១.៨. ឈ្មោះ [redacted] **គុយហេង** ចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្ដាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២៣ ទុកជាបានការដដែល និងសូមបន្ថែមថាខ្លួន និងបក្ខពួកមានគ្នាសរុបចំនួន ០៧នាក់បានជិះម៉ូតូចំនួន ០៣គ្រឿង ខ្លួនជិះជាមួយឈ្មោះ **គីមហុង** ខ្លួនជាអ្នកឌុបឈ្មោះ **គីមហុង** គាត់ជាអ្នកកាន់ផ្គាក់ ទៅព្រែកទុំដើម្បីវាយជនរងគ្រោះមិនស្គាល់ឈ្មោះ ហើយនៅពេលដែលពួកខ្លួនទៅដល់ភាគីម្ខាងទៀតបានរត់បាត់អស់ មិនទាន់បានកាប់ទេ។ ពួកខ្លួនធ្លាប់មានគំនុំជាមួយភាគីម្ខាងទៀតកាលពី ១ខែមុន រឿងពួកនោះវាយម៉ូតូពួកខ្លួន។ ពេលសមត្ថកិច្ចឃាត់ខ្លួនមិនបានដកហូតអ្វីទេ។ ហើយខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀនទេ។ ខ្លួនសូមសំណូមពរឱ្យតំណាងអយ្យការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

**១.៩. ឈ្មោះ [redacted] គុយហេង** ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយនៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាលទុកជាបានការដដែល។ នៅក្នុងរឿងនេះ ខ្លួនពិតជាបានប្រព្រឹត្តដូចតំណាងអយ្យការចោទប្រកាន់មែន។ សមត្ថកិច្ចបានឃាត់ខ្លួន កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២១ និង ៣០នាទី ខ្លួន និងបក្ខពួកចំនួន ០៧នាក់ បានជិះម៉ូតូចំនួន ០៣គ្រឿង ប្រដាប់ដោយដាវចំនួន ០១ដើម បានជិះទៅដេញកាប់ជនរងគ្រោះប្រហែល ៣ ទៅ ៤នាក់ ប្រាកដមែន ប៉ុន្តែ មិនទាន់បានកាប់ឡើយ ស្រាប់តែជនរងគ្រោះនាំគ្នារត់គេចអស់ទៅ។ សូមបញ្ជាក់ថា ខ្លួនជាអ្នកជិះម៉ូតូឌុបឈ្មោះ [redacted] **គីមហុង** ដោយមិនមានកាន់អ្វីទៅជាមួយឡើយ។ មូលហេតុដែល ខ្លួនទៅដេញកាប់ជនរងគ្រោះ ព្រោះឈ្មោះ [redacted] **ឈាន** បានហៅទូរស័ព្ទបបួលខ្លួនទៅកាប់គេ។ ហើយសូមបញ្ជាក់ថា ខ្លួនមិនដែលមានទំនាស់ដោយផ្ទាល់ជាមួយជនរងគ្រោះ និងមិនដែលស្គាល់គ្នាពីមុនឡើយ។ កន្លងមក ខ្លួនមិនដែលប្រព្រឹត្តសកម្មភាពបែបនេះឡើយ ហើយលើកនេះជាលើកទី ០១តែប៉ុណ្ណោះ។ ខ្លួនសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ដើម្បីឱ្យខ្លួនឆាប់បានចូលរៀនវិញ។

**១.១០. ឈ្មោះ [redacted] ហុងស្រេង** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង ៣០នាទី ឈ្មោះ [redacted] **សាន់** ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ ដំឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខ បានជិះទៅយកខ្លួនតែឯង និងប្រាប់ថានាំខ្លួនទៅដើរលេងមើលកុនជាមួយក្រុមពួកនៅអន្លង់តាសេក នៅវត្តអន្លង់តាសេកស្ថិតនៅក្នុងភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្តាល។ លុះនៅពេលមើលកុនរួចហើយនៅ វេលាម៉ោង ២១ និង ៣០នាទី រូបខ្លួន និងបក្ខពួកជាង ១០នាក់ មានកាន់ដាវ កាំបិតផ្គាក់ជិះម៉ូតូ ០៣គ្រឿង ដោយមានឈ្មោះដូចតទៅ ខ្លួនផ្ទាល់ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស អាយុ ១៧ឆ្នាំ ភូមិតាឧន ឃុំដូង ស្រុកបាទីខេត្តតាកែវ ជាអ្នកជិះនៅពីក្រោយម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ កែឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខ និងជាអ្នកកាន់កាំបិតផ្គាក់ ឈ្មោះ [redacted] **សាន់** ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ ដំឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខជាអ្នកបើកម៉ូតូ ឈ្មោះ **ហុង** ភេទប្រុស អាយុ ១៩ឆ្នាំ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២២ ពណ៌ស មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់កាំបិតផ្គាក់ ឈ្មោះ **ហុង ភេទ**ប្រុស ២១ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្ត

កណ្តាល ជាអ្នកជិះពីក្រោយម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១៨ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកកាន់ដាវ។ នៅមាន ០៤នាក់ទៀតដែលខ្លួនមិនស្គាល់ឈ្មោះ អ្នកកាន់ដុំថ្មចាំគប់។ ក្រៅពីនេះខ្លួនមិនស្គាល់អ្នកណាទៀតទេ។ លុះនៅពេលជួបជុំគ្នាអស់ហើយ រូបខ្លួនរួម និងបក្ខពួកបាននាំគ្នាជិះម៉ូតូនៅតាមផ្លូវជាតិលេខ២១ សំដៅទៅកាប់ក្រុមពួកPT នៅចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល តែម្តង។ បន្ទាប់ពីធ្វើសកម្មភាពរួចហើយ

ពួកខ្លួនក៏បាននាំគ្នាទៅផេកវិញរៀងៗខ្លួនអស់ទៅ។ ក្រោយមកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០ នាទី ទើបសមត្ថកិច្ចនាំខ្លួន មកសាកសួរនៅអធិការដ្ឋាននគរបាលស្រុកកោះធំតែម្តង។

១.១១. ឈ្មោះ [redacted] ហុងស្រេង ចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសូមបន្ថែមថាខ្លួន និងបក្ខពួកមានគ្នាសរុបចំនួន ០៧នាក់មានឈ្មោះ សាល, ហុង, គីមហុង, គុយហេង, សាន់ និង ណា ពិតជាបានជិះម៉ូតូចំនួន ០៣គ្រឿង ទៅធ្វើសកម្មភាពរកទៅវាយពួកព្រែកទុំ ដោយពេលនោះខ្លួនបានកាន់ដុំថ្ម ០១ មិនទាន់បានគប់ផងក៏ស្រាប់តែជនរងគ្រោះ បាននាំគ្នារត់ចូលផ្ទះបាត់អស់។ ក្នុងរឿងនេះឈ្មោះ ហុង ជាអ្នកផ្តើមគំនិតបបួលខ្លួន។ ពេលសមត្ថកិច្ចឃាត់ខ្លួន មិនបានដកហូតអ្វីទេ។ ហើយខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀនទេ។ ខ្លួនសូមសំណូមពរឱ្យតំណាងអយ្យការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

១.១២. ឈ្មោះ [redacted] ហុងស្រេង ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល និងសូមបដិសេធចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ត្រង់ចំណុចថា ខ្លួនជិះម៉ូតូពីក្រោយកាន់កាំបិតផ្គាក់។ តាមពិតនៅពេលខ្លួនត្រឡប់ពីដេញកាប់គេវិញទេ ទើបខ្លួនជាអ្នកកាន់កាំបិតផ្គាក់មកវិញ។ នៅក្នុងរឿងនេះ ខ្លួនពិតជាបានប្រព្រឹត្តដូចតំណាងអយ្យការចោទប្រកាន់មែន។ សមត្ថកិច្ចបានឃាត់ខ្លួន កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ សមត្ថកិច្ចបានឃាត់ខ្លួន កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅចំណុចផ្ទះរបស់ឈ្មោះ [redacted] សាន់ នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល។ ហើយពេលឃាត់ខ្លួន សមត្ថកិច្ចមិនបានដកហូតអ្វីពីខ្លួនឡើយ។ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២១ និង ៣០នាទី ខ្លួន និងបក្ខពួកចំនួន ០៧នាក់ បានជិះម៉ូតូចំនួន ០៣គ្រឿង ទៅដេញកាប់ជនរងគ្រោះចំនួន ០៤នាក់ (មិនស្គាល់ឈ្មោះ) ប្រាកដមែន ប៉ុន្តែកាប់មិនបានឡើយ ដោយសារជនរងគ្រោះបាននាំគ្នារត់ចូលផ្ទះរបស់គេទាន់។ មូលហេតុដែលខ្លួន និងបក្ខពួកនាំគ្នាញទៅដេញកាប់ជនរងគ្រោះ ព្រោះឈ្មោះ ហុង ភេទប្រុស ជាអ្នកបបួលខ្លួនទៅ ហើយខ្លួនមិនដែលស្គាល់ជនរងគ្រោះ ក៏មិនដែលមានទំនាស់អ្វីជាមួយគ្នាដែរ។ ខ្លួនសូមសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ខ្លួនដឹងកំហុសហើយ។

១.១៣. ឈ្មោះ [redacted] រក្សា ហៅ នី ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១៩ និង ០០នាទី ខ្លួន និងឈ្មោះ [redacted] ឈាន ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិពោធិរាម្នា សង្កាត់ព្រែកស្តី ក្រុងសំពៅលូន ខេត្តកណ្តាល បានជិះម៉ូតូហុងដាឌ្រីម ពណ៌ខ្មៅ សេរីឆ្នាំ២០២២ មិនថាំផ្លាកលេខ ក្នុងគោលបំណងទៅចូលរួមកម្មវិធីបុណ្យកឋិន នៅព្រែកចាន់ ស្ថិតនៅសង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល។ ក្រោយពេលត្រឡប់ពីបុណ្យកឋិនវិញពួកខ្លួនក៏នាំគ្នារកទៅលេងនៅឯក្រុងភ្នំពេញ រួមជាមួយបក្ខពួកប្រហែលជាង ២០នាក់ដោយមានយកកាំបិតផ្គាក់ ០៣ដើម ហើយនិងដុំឥដ្ឋ មួយចំនួន យកទៅជាមួយផងដែរ។ ដោយមានឈ្មោះដូចតទៅ ខ្លួនផ្ទាល់ឈ្មោះ [redacted] រក្សា ហៅ នី ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិ ប្រជាធុ(ក) សង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល ជិះម៉ូតូម៉ាកហុងដាឌ្រីម ០២២ ពណ៌ខ្មៅ មិនថាំផ្លាកលេខរូបខ្លួនជាអ្នកជិះនៅកណ្តាល និងជាអ្នកកាន់កាំបិតផ្គាក់ដងវែង ១ ដើម។ ឈ្មោះ [redacted] ឈាន ភេទប្រុស អាយុ ១៦ឆ្នាំ រស់



Scanned with CamScanner

នៅភូមិប្រធាតុ(ខ) សង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម ០២២ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកជិះម៉ូតូនៅពីក្រោយ និងកាំបិតផ្គាក់ដងខ្លី ០១ ដើម ឈ្មោះ **ហុង** ភេទប្រុស អាយុ ១៩ឆ្នាំ រស់នៅភូមិកោះចាស់ សង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម ០២២ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកបើកម៉ូតូ។ ឈ្មោះ [redacted] **នុន** ភេទប្រុស អាយុ ១៦ឆ្នាំ រស់នៅភូមិពោធិរាម្នា សង្កាត់ព្រែកស្តី ក្រុងសំពៅលូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម០១៨ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកបើកម៉ូតូ។ ឈ្មោះ **នីន** ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិខ្ពប់ ឃុំខ្ពប់ ស្រុកស្អាង ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម០២២ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់កាំបិតផ្គាក់ដងខ្លី។ ឈ្មោះ **ឡៀត** ភេទប្រុស អាយុ ១៥ឆ្នាំ រស់នៅភូមិប៉ុក សង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម ០១៩ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកជិះនៅកណ្តាលកាន់ដុំឥដ្ឋ។ ឈ្មោះ **នេត** ភេទប្រុស អាយុ ១៥ឆ្នាំ រស់នៅភូមិប៉ុក សង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម ០១៩ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់ដុំឥដ្ឋ។ ឈ្មោះ **ណាក់** ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅសង្កាត់សំពៅពូន ក្រុងសំពៅពូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម ០២២ ពណ៌ស មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់ដុំឥដ្ឋ។ ឈ្មោះ **ឡាយ** ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិពោធិរាម្នា សង្កាត់ព្រែកស្តី ក្រុងសំពៅលូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម មិនចាំសេរី ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកជិះនៅកណ្តាលកាន់ដុំឥដ្ឋ។ ឈ្មោះ **អាយ** ភេទប្រុស អាយុ ១៥ឆ្នាំ រស់នៅភូមិកោះចាស់ សង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល ជិះម៉ូតូហុងដាឌ្រីម មិនចាំសេរី ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់ដុំឥដ្ឋ។ ក្រៅពីនេះខ្លួនមិនស្គាល់នរណាទៀតនោះទេ។ បន្ទាប់ពីបានជួបជុំគ្នាអស់ហើយ ខ្លួនរួមនិងបក្សពួកក៏បានជិះម៉ូតូធ្វើដំណើរតាមផ្លូវជាតិលេខ២១ ពីត្បូងទៅជើង លុះនៅវេលាម៉ោង ២០ និង ៤០នាទី ពួកខ្លួនក៏ជិះម៉ូតូមកដល់ចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល ភ្លាមៗនោះស្រាប់តែខ្លួនបានឃើញក្មេងទំនើងជាច្រើនអ្នកដែលធ្លាប់មានរឿងរាវទាស់គ្នាជាមួយខ្លួនតាំងពីដើមនោះ បានធ្វើសកម្មភាពយកដុំឥដ្ឋគប់មកលើក្រុមពួកខ្លួន និងខ្លួនជាច្រើនដុំឥដ្ឋតែមិនត្រូវនោះទេ ភ្លាមទៀតនោះស្រាប់តែក្រុមពួកដួលម៉ូតូ ពេលពួកក្រុងទាំងនោះឃើញពួកខ្លួនដួលម៉ូតូហើយ ក៏នាំគ្នាជាច្រើននាក់ មកមានទាំងចំពាមកៅស៊ូ ដុំថ្ម កាំបិតផ្គាក់ រត់សំដៅមកកាប់រូបខ្លួន ព្រមទាំងក្រុមពួកខ្លួន ឃើញដូចនេះ ខ្លួននិងក្រុមខ្លួនក៏បានទាញកាំបិតចេញពីខោរ ខ្លះចេញពីអាវ ខ្លះចេញពីក្នុងម៉ូតូយកទៅដេញកាប់តបតវិញតែម្តង។ លុះពេលប្រយុទ្ធគ្នាបានមួយសន្ទុះពួកក្រុមក្មេងទំនើងដែលនៅព្រែកទុំនោះបាននាំគ្នារត់បាត់ទៅ រួចហើយពួកខ្លួនក៏បាននាំគ្នាជិះម៉ូតូត្រឡប់មកផ្ទះវិញរៀងៗខ្លួនតែម្តង។ក្រោយ មកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០នាទី ទើបសមត្ថកិច្ចបាននាំខ្លួន មកសាកសួរនៅអធិការដ្ឋាននគរបាលស្រុកកោះធំតែម្តង។

**១.១៤. ឈ្មោះ** [redacted] **រក្សា ហៅ ឌី** ចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសូមបន្ថែមថាខ្លួន និងបក្ខពួកមានគ្នាសរុបចំនួន ២០នាក់មានឈ្មោះ នុន, ឈាន, ហុង រីឯអ្នកផ្សេងទៀតមិនស្គាល់ឈ្មោះ ពិតជាបានជិះម៉ូតូចំនួន ១០គ្រឿង ទៅធ្វើសកម្មភាពរកទៅវាយពួកព្រែកទុំ ដោយពេលនោះខ្លួនជិះ

ជាមួយឈ្មោះ ហុង ដោយខ្លួនជាអ្នកកាន់កាំបិតផ្គាក់ ពេលទៅដល់កន្លែងកើតហេតុក្រុមខ្លួន បានវាយ ប្រតាយប្រតប់ និងគប់គ្នាទៅវិញទៅមកជាមួយជនរងគ្រោះ បន្ទាប់មកភាគីជនរងគ្រោះក៏បានរត់គេចខ្លួនបាត់អស់។ ខ្លួនបានកាប់ដែរ តែមិនមានអ្នករងរបួសញទេ។ កន្លងមកខ្លួនធ្លាប់ឈ្លោះគ្នាជាមួយពួកជនរងគ្រោះពីរដងហើយ។ ពេលសមត្ថកិច្ចឃាត់ខ្លួន មិនមានដកហូតអ្វីទេ។ ហើយខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀនទេ។ ខ្លួនសូមសំណូមពរឱ្យតំណាងអយ្យការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

១.១៥. ឈ្មោះ [redacted] រក្សា ហៅ ដី ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយនៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាលទុកជាបានការដដែល។ នៅក្នុងរឿងនេះខ្លួនពិតជាបានប្រព្រឹត្តដូចតំណាងអយ្យការចោទប្រកាន់មែន។ សមត្ថកិច្ចបានឃាត់ខ្លួន កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១៨ និង ៣០នាទី ខ្លួន និងឈ្មោះ [redacted] ឈាន បាននាំគ្នាជិះម៉ូតូហុងដាឌ្រីមសេរីឆ្នាំ២០១៦ ឡើងសេរីឆ្នាំ២០២២ ដែលជាម៉ូតូរបស់ឪពុកខ្លួនហើយឈ្មោះ [redacted] ឈាន ជាអ្នកឌុបខ្លួនដើម្បីទៅលេងបុណ្យកឋិន ព្រោះនៅមានគេដាក់ធុងបាស់ដែលស្តិត នៅសង្កាត់ព្រែកស្តី ក្រុងសំពៅពូន ខេត្តកណ្តាល។ បន្ទាប់មក ខ្លួនជួបជាមួយបក្ខពួករបស់ខ្លួននៅកន្លែងបុណ្យកឋិន មានគ្នាប្រហែល ២០នាក់ តែមិនចាំឈ្មោះពួកវាទេ ដោយខ្លួនចាំបានតែឈ្មោះ [redacted] ឈាន។ លុះប្រហែល០២ ម៉ោងក្រោយមក ខ្លួន និងបក្ខពួកប្រហែល ២០នាក់ ក៏បានបបួលគ្នាជិះម៉ូតូប្រហែល ១០គ្រឿងដោយមានយកមកជាមួយនៅ កាំបិតផ្គាក់ចំនួន ០៣ដើម និងដុំឥដ្ឋមួយចំនួន ឡើងទៅភ្នំពេញ ហើយនៅពេលដែលខ្លួន និងបក្ខពួកជិះម៉ូតូដល់ចំណុចភូមិព្រែកបិ ក៏បានប្រទះឃើញក្មេងទំនើងជាច្រើននាក់ (មិនចាំចំនួន) បានចេញមកគប់ដេញកាប់ និងបាញ់ចំពាមកៅស៊ូមកលើ បក្ខពួកខ្លួន បណ្តាលឱ្យបក្ខពួកខ្លួនដួលម៉ូតូ ចំនួន ០១ម៉ូតូ ភ្លាមនោះខ្លួន និងបក្ខពួក បានចុះវាយគ្នាទៅវិញទៅមក។ បន្ទាប់ពីដេញវាយគ្នាបានមួយសន្ទុះ ក្មេងទំនើងមួយក្រុងនៅភូមិព្រែកបិ បាននាំគ្នារត់គេចខ្លួនអស់ រួចខ្លួន និងបក្ខពួកក៏បានជិះម៉ូតូត្រឡប់មកផ្ទះរៀងៗខ្លួនអស់ទៅ។ សូមបញ្ជាក់ថានៅពេលវាយគ្នានោះ ខ្លួនបានយកកាំបិតផ្គាក់ទៅកាប់ភាគីម្ខាងទៀតដែរ ប៉ុន្តែមិនត្រូវឡើយ ហើយភាគីម្ខាងទៀត គឺខ្លួនមិនស្គាល់ឈ្មោះពួកវាទេ។ ចំពោះភាគីម្ខាងទៀតនោះ ខ្លួនមិនដឹងថាមានអ្នករងរបួស ឬ អត់ទេ តែចំណែកបក្ខពួកខ្លួនគឺឈ្មោះ [redacted] ឈាន បានបាក់ជើងដែលបណ្តាលមកពីការដួលម៉ូតូនៅពេលនោះ។ សូមបញ្ជាក់ថា នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ គឺមានការដេញកាប់គ្នា គប់គ្នាចំនួន ០២ លើកជាមួយក្មេងទំនើងនៅភូមិព្រែកបិ ដោយលើកទី ០១ គឺបក្ខពួករបស់ឈ្មោះ ស៊ិន វិសាល ចំណែកលើកទី ០២ គឺបក្ខពួកខ្លួនចំនួនប្រហែល ២០នាក់។ សូមបញ្ជាក់ថាខ្លួនមិនចេះប្រើប្រាស់គ្រឿងញៀនឡើយ។ នៅក្នុងរឿងនេះ ខ្លួនដឹងកំហុសរបស់ខ្លួនហើយ។

១.១៦. ឈ្មោះ [redacted] គីមហុង ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២២ និង ៣០នាទី ខ្លួនរួម និងបក្ខពួកចំនួន ០៨នាក់ ម៉ូតូ ០៣គ្រឿងបាននាំគ្នាយកកាំបិតផ្គាក់ ដុំថ្ម បំពង់ទីបទៅធ្វើសកម្មភាពដេញកាប់ និងវាយទៅលើក្រុមក្មេងទំនើងដែលធ្លាប់មានទំនាស់ជាមួយ ខ្លួន និងមិត្តភ័ក្តិ នៅចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល ដែលមានឈ្មោះដូចតទៅរួបខ្លួនផ្ទាល់ ជាអ្នកជិះម៉ូតូហុងដាឌ្រីម០២០ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជិះពីក្រោយកាន់ដាវ។ ឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ ១៧



Scanned with CamScanner

ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្តាល ជាអ្នកជិះម៉ូតូវីវ៉ា ពីក្រោយកាន់ដំបងទីប ឈ្មោះ ជំ ភេទប្រុស អាយុ ១៦ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្តាល ជាអ្នកជិះម៉ូតូវីវ៉ា កណ្តាលកាន់ដុំឥដ្ឋ ឈ្មោះ ស្រួយ ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្តាល ជាអ្នកជិះម៉ូតូស្កាក់វី និងជាអ្នកបើកបរម៉ូតូ និង ០៤ នាក់ទៀតមិនស្គាល់ឈ្មោះនោះទេ។ លុះមកដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២១ និង ៣០ នាទី ខ្លួនរួមនិងបក្ខពួកចំនួន ០៧ នាក់មានដូចតទៅ ខ្លួនផ្ទាល់ ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅមិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់កាំបិតផ្គាក់ ឈ្មោះ [redacted] គុយហេង ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិជំនិក ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ ជាអ្នកបើកបរម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២០ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ឈ្មោះ [redacted] សាន់ ភេទប្រុស អាយុ ១៧ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ ដែរឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខជាអ្នកបើកម៉ូតូ ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស អាយុ ១៧ឆ្នាំ ភូមិតានន ឃុំដូង ស្រុកបាទី ខេត្តតាកែវ ជាអ្នកជិះនៅពីក្រោយម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២១ កែឡើង២០២២ ពណ៌ស មិនចាំផ្លាកលេខ និងជាអ្នកកាន់កាំបិតផ្គាក់ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៥ ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១២ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជិះពីក្រោយ ឈ្មោះ ណាក់ ភេទប្រុស ១៦ឆ្នាំ រស់នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ជាអ្នកបើកម៉ូតូ ឈ្មោះ ហុង ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ ជាអ្នកជិះម៉ូតូហុងដាឌ្រីម សេរីឆ្នាំ២០២២ ពណ៌ស មិនចាំផ្លាកលេខ ជាអ្នកជិះពីក្រោយកាន់ដាវ លុះពេលខ្លួនបានត្រលប់មកពីមើលកុននៅបុណ្យកឋិនវិញមក នៅវេលាម៉ោង ២១ និង ៣០នាទី ថ្ងៃខែឆ្នាំដដែល នៅពេលជិះដល់ចំណុចភូមិព្រែកបិ ឃុំកោះធំ (ខ) ស្រុកកោះធំ ខេត្តកណ្តាល ស្រាប់តែពួកខ្លួនបានជួបនិងក្រុមពួកក្មេងទំនើងដែលធ្លាប់មានទំនាស់ជាមួយពួកខ្លួនកាលពីមុន ពួកខ្លួនក៏នាំគ្នាយកដេញកាប់ដេញវាយក្រុមក្មេងទំនើងទាំងអស់តែម្តង។ ក្រោយមកក្រុមពួកក្មេងទំនើងទាំងនោះក៏បាននាំគ្នារត់អស់ទៅ បន្ទាប់មកពួកខ្លួនក៏បាននាំគ្នាត្រឡប់មកផ្ទះវិញរៀង១ខ្លួនទៅ។ បន្ទាប់ពីសកម្មភាពរួចហើយពួកខ្លួនក៏នាំគ្នាទៅដេកវិញរៀង១ខ្លួនអស់ទៅ។ ក្រោយមកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០នាទី ទើបសមត្ថកិច្ចនាំខ្លួនរូបខ្លួនមកសាកសួរនៅអធិការដ្ឋាននគរបាលស្រុកកោះធំតែម្តង។

**១.១៧.** ឈ្មោះ [redacted] គឹមហុង នៅចំពោះមុខតំណាងអយ្យការថា៖ ខ្លួនសូមរក្សាទុកចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសូមបញ្ជាក់ថា ខ្លួន និងបក្ខពួកមានគ្នា ០៧ នាក់ ពិតជាបានបបួលគ្នាទៅធ្វើសកម្មភាពវាយពួកព្រែកទុំ ដោយខ្លួនកាន់កាំបិតផ្គាក់ ជិះជាមួយនឹងឈ្មោះ គុយហេង ពេលទៅដល់មិនទាន់បានវាយផង ពួកវាបានរត់បាត់អស់ទៅហើយ។ ខ្លួនឈ្មោះជាមួយភាគីម្ខាងទៀតដោយសារតែពួកនោះធ្លាប់វាយពួកខ្លួន។ ពេលសមត្ថកិច្ចឃាត់ខ្លួនមិន មានដកហូតអ្វីទេ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល ០៣ ខែមកហើយ មុនពេលសមត្ថកិច្ចឃាត់ខ្លួន ០២ ថ្ងៃ បានប្រើប្រាស់ថ្នាំញៀននៅផ្ទះ។ ខ្លួនសំណូមពរអយ្យការបន្ធូរបន្ថយទោសដល់ខ្លួនផង។



Scanned with CamScanner

១.១៨. ឈ្មោះ [redacted] គីមហុង នៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ក្នុងរឿងនេះ ខ្លួនពិតជាបានប្រព្រឹត្តអំពើដូចតំណាងអយ្យការចោទប្រកាន់មែន។ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ២១ និង ៣០ នាទី ខ្លួន និងបក្ខពួកចំនួន ០៦ នាក់ បានជិះម៉ូតូចំនួន ០៣ គ្រឿង ទៅដេញកាប់ក្មេងទំនើង មួយក្រុមនៅព្រៃកុំ ប្រាកដមែន ប៉ុន្តែកាប់មិនបានឡើយ ដោយសារតែក្មេងទំនើងមួយក្រុមនោះ បាននាំគ្នារត់ គេចខ្លួនអស់។ ខ្លួនសូមបញ្ជាក់ថា នៅពេលសមត្ថកិច្ចឃាត់ខ្លួនបានធ្វើតេស្តិ៍ទឹកនោមលើខ្លួន ជាលទ្ធផលវិជ្ជមាន សារធាតុញៀន (+)។ នៅក្នុងរឿងនេះឈ្មោះ [redacted] គួយហេង ជាអ្នកផ្តើមគំនិត ហើយខ្លួនមិនដែលមានទំនាស់និងមិនស្គាល់គ្នាពីមុនឡើយ។

១.១៩. ឈ្មោះ ស៊ីន វិសាល នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ នៅថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១៨ ខ្លួនមិនទទួលស្គាល់ទេ។

១.២០. ឈ្មោះ [redacted] សាន់ នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ ខ្លួនមិនទទួលស្គាល់ទេ។

១.២១. ឈ្មោះ [redacted] ហុងស្រេង នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ ខ្លួនទទួល ស្គាល់។

១.២២. ឈ្មោះ [redacted] គុយហេង នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ ខ្លួនទទួល ស្គាល់។

១.២៣. ឈ្មោះ [redacted] រក្សា នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ ខ្លួនទទួលស្គាល់។

១.២៤. ឈ្មោះ [redacted] គីមហុង នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ ខ្លួនមិនទទួល ស្គាល់ទេ រឿងហិង្សាទេ តែខ្លួនទទួលស្គាល់ថាខ្លួនពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

១.២៥. ឈ្មោះ [redacted] ហុងស្រេង នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានជិះជាមួយនឹងឈ្មោះ [redacted] សាន់ ក្រោយមកខ្លួនក៏ជិះចូលកន្លែងនោះតែមិនបានប៉ះពាល់ក្រុមជនរងគ្រោះទេ ហើយក៏មិនដឹងថា អ្នកណាកាន់ដុំថ្មទេ។ ក្រុមទៅមាន ៥ នាក់ ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] គុយហេង។ ឈ្មោះ [redacted] រក្សា មិនពាក់ព័ន្ធនោះទេ។ ខ្លួនជិះជាមួយឈ្មោះ [redacted] សាន់ ពួកខ្លួនជិះ ០៣ ម៉ូតូ។ ឈ្មោះ [redacted] គីមហុង មិនដឹងជិះជាមួយអ្នកណា។ ពួកខ្លួនចេញពីវត្តសំដៅទៅធ្វើ សកម្មភាពត្រង់ចំណុចគេហូបអី។ ខ្លួនពុំស្គាល់ ០១ ក្រុមទៀតទេ ឈ្មោះ [redacted] សាន់ ជាអ្នកបបួលខ្លួនទៅ។ ពេលនោះខ្លួនពុំមានម៉ូតូជិះខ្លួនក៏ទៅជាមួយនឹងឈ្មោះ [redacted] សាន់ ទៅ។ កាំបិតដុំថ្ម ខ្លួនមិនដឹងនោះទេ។ ពីវត្តទៅកន្លែង កើតហេតុមិនដឹងថាជិតឬឆ្ងាយទេ។ កើតហេតុម៉ោងប្រហែល ៨ យប់។ ពេលទៅដល់ឃើញក្រុមម្ខាងទៀតអើតកមកដោយក្រុមខ្លួនពុំទាន់ធ្វើអ្វីទេ ស្រាប់តែជិះចូលក្រុមម្ខាងទៀតរត់ផ្អើលអស់តែម្តង។ ខ្លួនពុំធ្លាប់ស្គាល់ ក្រុមម្ខាងទៀតនោះទេ។ ពុំមានការយកកាំបិតផ្គាក់ដេញកាប់ទេ ចំណែកដុំថ្មពុំមានដែរ។ អ្នកកាន់កាំបិតផ្គាក់ខ្លួន ពុំដឹងនោះទេ តែខ្លួនកាន់ពេលត្រឡប់មកវិញ។ អ្នកកាន់ទៅគឺឈ្មោះ ហុង។ ខ្លួនសូមបញ្ជាក់ថាពេលជិះទៅពុំបាន កាន់កាំបិតទេ ខ្លួនកាន់ពេលត្រឡប់មកវិញ។ ចំពោះកាបិតគឺឈ្មោះ ហុង ជាអ្នកផ្ញើនឹងខ្លួនដោយពេលផ្ញើនឹងគឺ ពេលត្រឡប់មកវិញ។ ឈ្មោះ ហុង ពីងឱ្យខ្លួនកាន់យកមកវិញ។ នៅថ្ងៃកើតហេតុចេញពីមើលកុន ហើយសំដៅ ទៅរកជនរងគ្រោះ ខ្លួនដឹងថា មានកាំបិត ០១ ដើម ដាវ ០១ ដើម ដែរតែមិនដឹងអ្នកណាកាន់ទេ។ ពួកខ្លួនមិនបាន កាប់ៈទៅលើជនរងគ្រោះទេ ហើយក៏មិនបានកាន់ដុំថ្មគប់ទៅលើជនរងគ្រោះដែរ។ ពួកខ្លួនគ្រាន់តែជិះចូលស្រាប់ តែខាងជនរងគ្រោះជិះចេញតែម្តង។ ខ្លួនសូមបញ្ជាក់ថា ជិះទៅខ្លួនមិនមានកាន់កាំបិតនោះទេ ពេលខ្លួនទៅ គឺខ្លួនកាន់ដុំថ្ម។ ពេលខ្លួនចេញពីផ្ទះគឺទាបភ្លឺ គឺឈ្មោះ [redacted] សាន់ ជាអ្នកមកយកខ្លួន គោលបំណងទៅដើរលេងនៅស្រុកកាត់

ប្រហែលម៉ោង ១០ យប់ ទើបគេប្រកាសត្រឡប់មកវិញ។ ចេញពីកន្លែងដើរលេងម៉ោង ២ ថ្ងៃត្រង់ឈ្មោះ [redacted] សាន់ ឱ្យខ្លួនទៅអង្គុយលេងជាមួយគាត់ រហូតដល់ម៉ោង ៨ យប់ ហើយឈ្មោះ លី សាន់ បបួលខ្លួនទៅរកគេឈ្មោះ លី សាន់ ប្រាប់ថា "ធ្លាប់មានរឿងជាមួយក្រុមនេះ"។ មូលហេតុដែលខ្លួនទៅដោយសារតែថ្ងៃកើតហេតុ ដោយសារខ្លួនពុំមានម៉ូតូជិះ។ សកម្មភាព ០១ ក្រុមទៀតគ្រាន់តែដើរ ៗ មក ពួកខ្លួនក៏ជិះម៉ូតូបៀនជិះចូលទៅ ក្រុមជនរងគ្រោះក៏បំបែកហ្វូងគ្នាទៅ។

១.២៦. ឈ្មោះ [redacted] គុយហេង នៅក្នុងកិច្ចពិភាក្សាដេញដោល៖ ថ្ងៃកើតហេតុ ខ្លួនទៅមើលកុនទៅវត្ត បន្ទាប់មកឈ្មោះ [redacted] សាន់ បានបបួលខ្លួនទៅកន្លែងកើតហេតុ ដើម្បីទៅរករឿងម្ខាងទៀត ដែលធ្លាប់ឈ្មោះជាមួយគាត់។ ពេលទៅដល់កន្លែងកើតហេតុ ឃើញមានអ៊ុំផ្សពេញផ្លូវ ហើយភាគីជនរងគ្រោះ រត់ចេញ។ ខ្លួនមិនមែនអ្នកគប់។ ខ្លួនទៅ ០៣ ម៉ូតូ គ្នា ០៧ នាក់ ជិះជាមួយនឹងឈ្មោះ [redacted] គីមហុង។ ខ្លួនមិន ធ្លាប់ស្គាល់ជនរងគ្រោះទេ។ ខ្លួនឌុបឈ្មោះ [redacted] គីមហុង ខ្លួនក៏ជិះតាមផ្លូវលំ ហើយជនរងគ្រោះក៏រត់ធ្លើសតែ ម្តង។ ខ្លួនដឹងថាមានកាំបិតផ្គាក់តែមិនដឹងអ្នកណាកាន់ទេពេលទៅ ។ មកដល់ផ្ទះឈ្មោះ [redacted] គីមហុង ជាអ្នក កាន់ត្រឡប់មកវិញ។ ខ្លួនសូមបញ្ជាក់ថា ពេលត្រឡប់ឈ្មោះ [redacted] គីមហុង អ្នកកាន់កាំបិតតែមិនទាន់បានកាប់ ទេទៅដល់ជនរងគ្រោះរត់បាត់។ ពេលទៅឈ្មោះ [redacted] គីមហុង មិនបានកាន់អ្វី។ ឈ្មោះ [redacted] សាន់ ជាអ្នកបបួល គ្នាទៅ។ ខ្លួនមិនបានកាប់ទេ។ ក្នុងពន្ធនាគារខ្លួនទទួលស្គាល់កំហុសរបស់ខ្លួន និងសន្យាកែប្រែ។ ពេលទៅដល់អ៊ុំផ្ស ពេញផ្លូវ។ ពេលទៅ ០៣ ម៉ូតូ ដំណើរគ្នា។ ពេលទៅដល់ក្រុមម្ខាងទៀតបានចេញមកថ្កល់ជាតិដែរ ។ ឈ្មោះ [redacted] ហុងស្រេង ខ្លួនពុំបានឃើញកាន់កាំបិត និងអ៊ុំផ្សទេ។ ពួកខ្លួនមិនបានប្រើហិង្សាលើក្រុមម្ខាងទៀតទេ ឈ្មោះ [redacted] វិសាល ក៏ទៅជុំពួកខ្លួនដែរ ដឹងថាឈ្មោះ [redacted] វិសាល ឌុប ០២ នាក់ទៀត តែខ្លួនមិនឃើញឈ្មោះ [redacted] វិសាល កាន់កាប់អាវុធក្នុងដៃឡើយ។

១.២៧. ឈ្មោះ [redacted] រក្សា នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ ថ្ងៃកើតហេតុខ្លួនទៅកឋិននៅវត្ត ក្រោយចេញពីកឋិនក៏ទៅភ្នំពេញ។ ក្រោយខ្លួនទៅជាមួយឈ្មោះ [redacted] ឈាន ឈ្មោះ ហុង (មិនបាន ចាប់មកជាមួយទេ) ឈ្មោះ ស្រេង និងឈ្មោះ ណុន។ ខ្លួនជិះជាមួយឈ្មោះ ដែន។ គោលដៅឡើងមកភ្នំពេញ គោលបំណងដើរលេង ជិះមកដល់ម្តុំកន្លែងកើតហេតុមានគេចេញមកគប់ក៏ជិះហួស ហើយបកត្រឡប់មកវិញ។ ខ្លួនទៅគ្នាប៉ុន្មាននាក់មិនចាំដឹងតែច្រើនគ្នា ប្រហែលជាង ១០ ម៉ូតូ។ ១០ ម៉ូតូនោះពុំមានឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] ហុងស្រេង ឈ្មោះ [redacted] គុយហេង តែមានឈ្មោះ [redacted] ឈាន។ ខ្លួនពុំស្គាល់ឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] ហុងស្រេង ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] គីមហុងនោះទេ ស្គាល់តែឈ្មោះ [redacted] ឈាន។ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ថ្ងៃសមត្ថកិច្ចឃាត់ខ្លួន។ គប់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ម៉ោង ៨ យប់។ ក្រុមរបស់ខ្លួនទៅដល់កន្លែងកើតហេតុគឺមានក្រុមផ្សេងទៀត តែក្រុមគេគប់ក្រុមរបស់ខ្លួនត្រូវដួលម៉ូតូ។ ចំណែកក្រុមខ្លួនត្រូវតែម៉ូតូប៉ុណ្ណោះ ខ្លួនបានឃើញក្រុមរបស់ខ្លួនចុះទៅជួយ ខ្លួនក៏រត់ ទៅជួយដែរ តែក្រុមរបស់គេរត់អស់។ ពួកម្ខាងទៀតពុំមានម៉ូតូទេ ក្រុមខ្លួនពុំបានវាយក្រុមម្ខាងទៀតនោះទេ។ ក្រុមម្ខាងទៀតពុំមានម៉ូតូនោះទេ។ ក្រុមខ្លួនគ្រាន់តែប្រតាយប្រតប់គ្នាច្រឡំ។ ក្រុមខ្លួនមានដាវ ០២ ដើម កាំបិតផ្គាក់ ០២ ដើម។ ពីដើមពុំ



Scanned with CamScanner

ធ្លាប់មានទំនាស់ទេ។ មូលហេតុយកអាវុធទៅដើម្បីការពារខ្លួន។ នៅថ្ងៃកើតហេតុមិនបានកាប់ត្រូវអ្នកណាទេ។ ពួកខ្លួនបានប្រកាយប្រតប់ជាមួយគ្នា។ ខ្លួនបានកាន់កាំបិតផ្គាក់ដោយជិះជាមួយឈ្មោះ ឆែន។ ឈ្មោះ [redacted] ជិះជាមួយឈ្មោះ [redacted] ធៀន ០១ នាក់ទៀត ខ្លួនមិនស្គាល់។ ដំបូងខ្លួនជិះជាមួយនឹងឈ្មោះ ឆែន ពេលត្រឡប់មកវិញជិះជាមួយនឹងឈ្មោះ ហុង។ ឈ្មោះ [redacted] ហុងស្រេង ឈ្មោះ [redacted] គុយហេង ខ្លួនពុំស្គាល់ទេ។ ឈ្មោះ [redacted] វិសាល ពុំស្គាល់តែមិនមែននៅក្នុងក្រុមរបស់ខ្លួននោះទេ។ ខ្លួនមិនដឹងថាឈ្មោះ វិសាល នៅក្នុងក្រុមណានោះទេ។ ចំពោះចម្លើយនៅចៅក្រមស៊ើបសួរ និងនៅរយៈការអានគឺត្រឹមត្រូវ។ ថ្ងៃកើតហេតុ ទៅជាមួយនឹងឈ្មោះ [redacted] ឈាន ឈ្មោះ ហុង ឈ្មោះ ឆែន និងឈ្មោះ ពក្ខន។ នៅម៉ោង ០៨ និង ៣០ នាទីខ្លួនចេញពីបុណ្យកឋិនឡើងមកភ្នំពេញ គោលបំណងដើរលេងប៉ុណ្ណោះ។ មូលហេតុដែលមានទំនាស់ជាមួយក្រុម ម្ខាងទៀតដោយសារតែជួបនឹងក្រុមរបស់ជនរងគ្រោះ ហើយក្រុមរបស់ជនរងគ្រោះបានយកដុំថ្មគប់មកលើក្រុមរបស់ខ្លួនមុន។ ពេលនោះក្រុមខ្លួនបានកាន់កាំបិតផ្គាក់មកដែរ តែមិនទាន់បានកាប់ទេ។

១.២៨. ឈ្មោះ [redacted] វិសាល នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ នៅថ្ងៃកើតហេតុ ចេញពីវត្តអន្លង់សេកចេញមកចំនួន ០៨ នាក់ ឈ្មោះ [redacted] គីមហុង ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] ហុងស្រេង និងពីរនាក់ទៀតឈ្មោះ [redacted] រក្សា ឈ្មោះ [redacted] ឈាន ខ្លួនមិនស្គាល់។ ឈ្មោះ [redacted] គីមហុង និងខ្លួនជិះម៉ូតូជាមួយគ្នា។ ខ្លួនជាអ្នកឌុបម៉ូតូជាមួយនឹងឈ្មោះ [redacted] គីមហុង។ គោលបំណងជិះដើរលេងប៉ុណ្ណោះ។ ស្រាប់តែឃើញគេរត់ចេញមកពីរនាក់។ ក្រុមរបស់ខ្លួនពុំបានដេញវាយក្រុមម្ខាងទៀតឡើយ ក្រុមរបស់ខ្លួនពុំមានកាំបិត ឬដាវទេ ដោយសារខ្លួនពុំបានកាន់អ្វីនោះទេ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនជិះនោះគឺគោលបំណងជិះដើរលេងប៉ុណ្ណោះ។ ខ្លួនសូមបញ្ជាក់ថា ដៃខ្លួនពុំមានកាន់អ្វីនោះទេ។ អ្វីដែលចៅក្រមអានឱ្យស្ដាប់គឺខ្លួនមិនបានប្រព្រឹត្តនោះទេ តែមិនទាន់បាន់ធ្វើសកម្មភាពឡើយ។ នៅថ្ងៃកើតហេតុ ខ្លួនជិះពីក្រោយ មិនបានកាន់កាំបិតទេ ហើយក៏ពុំបានធ្វើសកម្មភាពប្រកាយប្រតប់ដែរ។ ខ្លួនឌុបឈ្មោះ [redacted] គីមហុង។ ខ្លួនពុំធ្លាប់ស្គាល់ជនរងគ្រោះទេ។ ថ្ងៃកើតហេតុមាន ០២ ក្រុម តែខ្លួនមិនស្គាល់ ០១ ក្រុមទៀត ហើយក៏មិនធ្លាប់ស្គាល់ជនរងគ្រោះដែរ។ ដុំថ្ម និងកាំបិតគឺខ្លួនមិនបានកាន់ គឺអ្នកដែលទៅជាមួយខ្លួន។ ខ្លួនទៅមានគ្នា ០៨ នាក់។ ចំពោះអ្នករត់គេចខ្លួន ជាអ្នកកាន់ដាវ។ ខ្លួនដឹងថាក្រុមខ្លួនមានដុំថ្ម មានកាំបិត ដោយនិយាយថា "ជិះជុំគ្នា" តែអាវុធទាំងនោះមិនមែនខ្លួនជាអ្នកកាន់ទេ។ ជនរងគ្រោះខ្លួនធ្លាប់ជួប ០៤ ទៅ ០៥ ថ្ងៃ។ ឈ្មោះ [redacted] ហុងស្រេង ខ្លួនមិនស្គាល់ទេ ទើបឃើញនៅថ្ងៃកើតហេតុ តែក៏មិនឃើញឈ្មោះ [redacted] ហុងស្រេង កាន់អ្វីទេ ឈ្មោះ [redacted] គីមហុង កាន់ដាវ។ ពួកខ្លួនជិះ ០៣ ម៉ូតូ គោលបំណងកាប់ពួកវា។ ក្រុមជនរងគ្រោះស្គាល់តែពុំធ្លាប់មានទំនាស់ជាមួយគ្នាទេ។

១.២៩. ឈ្មោះ [redacted] សាន់ នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ នៅថ្ងៃកើតហេតុខ្លួន ជិះម៉ូតូជាមួយនឹងឈ្មោះ [redacted] ហុងស្រេង ខ្លួនជាអ្នកឌុបដោយជិះម៉ូតូរបស់ខ្លួន ដោយគម្រោងដើរលេងនៅភ្នំពេញ។ លុះជិះមកដល់កន្លែងកើតហេតុនៅព្រែកប៉ក់មានក្រុមមនុស្ស ០៤ នាក់ ដើរចេញមក ស្រាប់តែមនុស្ស ០៤ នាក់ នោះរត់គេចអស់។ មិត្តភក្តិដែលខ្លួនឃើញដើរមកខ្លួនស្មានតែមិត្តភក្តិ ដោយគ្រាន់តែឃើញពួកខ្លួន ក៏រត់គេចខ្លួន អស់ទៅ។ ចំពោះចម្លើយចៅក្រមអានឱ្យស្ដាប់គឺត្រឹមត្រូវ។ ពេលនោះពិតជាដេញកាប់គេមែន តែកាប់មិនបាន។ ក្រុមខ្លួន

មានដាវ ០១ ដើម ឈ្មោះ [redacted] គីមហុង កាន់ដុំថ្ម ឈ្មោះ [redacted] ហុងស្រេង កាន់ផ្គាក់ ឈ្មោះ ហុង ដែលរត់គេចជាអ្នកកាន់។ ពួកខ្លួនទៅគ្នា ០៧ នាក់ ០៣ ម៉ូតូ មានឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] គីមហុង ឈ្មោះ [redacted] ហុងស្រេង ពុំមានឈ្មោះ [redacted] គុយហេង ទេ ហើយក៏ពុំមានឈ្មោះ [redacted] រក្សា ដែរ។ ពួកខ្លួនមានបំណងទៅប្រព្រឹត្តតែកាប់ពុំទាន់បានកាប់ទេ។ ពេលពួកខ្លួនជិះម៉ូតូមកដល់ស្រាប់តែឃើញខាង ជនរងគ្រោះដើរចេញមក ស្រាប់តែបកម៉ូតូត្រឡប់មកវិញ ស្រាប់តែជនរងគ្រោះរត់គេចខ្លួន។ ពុំទាន់កាប់ ឬយកដុំថ្មគប់ឡើយ។ មុនទៅដល់កន្លែងកើតហេតុ ពុំឃើញមានសកម្មភាពអ្វីទេ ហើយក៏ពុំទាន់កាប់ទាន់ឃើញជនរងគ្រោះឡើយ។ ពួកខ្លួនមិនទាន់បានគប់ ឬកាប់ទៅលើជនរងគ្រោះទេ ដុំថ្ម និងកាំបិតនៅហ្នឹងដៃប៉ុណ្ណោះ។

១.៣០. ឈ្មោះ [redacted] គីមហុង នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ នៅថ្ងៃកើតហេតុ ខ្លួនជិះពីកន្លែងមើលកុន មានគ្នា ០៨ នាក់ ០៣ ម៉ូតូ ស្គាល់តែឈ្មោះ [redacted] គុយហេង ០១ ឈ្មោះ [redacted] សាត់ មិនស្គាល់ឈ្មោះ [redacted] វិសាល ក៏មិនស្គាល់។ ខ្លួនជិះជាមួយនឹងឈ្មោះ [redacted] គុយហេង គោលបំណងដើរ លេង។ ពេលជិះមកដល់ចំណុចកើតហេតុស្រាប់តែឃើញក្រុមម្ខាងទៀតដើរចេញមកខ្លួនក៏ជិះបកម៉ូតូត្រឡប់ទៅផ្ទះវិញ។ ខ្លួនឃើញក្រុមម្ខាងទៀតស្ទាក់ក៏បកត្រឡប់មកវិញ។ ចំពោះចម្លើយនៅចៅក្រមស៊ើបសួរអាចឱ្យ ស្តាប់ខ្លួនទទួលស្គាល់។ ពីដំបូងគឺមាន ០២ ក្រុមដែលទៅដំបូងគេដែរ ខ្លួនមិនដឹងក្រុមណានោះទេ ពុំមានអ្នកណាបបួលទេចិត្តចង់ទៅដើរលេងតែម្តង។ ចំពោះចម្លើយនៅអយ្យការមុនផ្តិតគឺគេអានឱ្យស្តាប់ខ្លួនទទួលស្គាល់។ ចំពោះក្រុមខ្លួន១ស្គាល់តែឈ្មោះ [redacted] ហុងស្រេង ប៉ុណ្ណោះ តែថ្ងៃកើតហេតុខ្លួនឃើញឈ្មោះ [redacted] វិសាល តែពុំឃើញកាន់អាវុធអ្វីឡើយ។

**២. ការស្តាប់ចម្លើយជនរងគ្រោះ**

២.១. ចម្លើយជនរងគ្រោះឈ្មោះ [redacted] ម៉េងហុន នៅក្នុងកិច្ចពិភាក្សាដេញដោលថា៖ ចំពោះរឿងហេតុខ្លួនមិនសូវចងចាំនោះទេ។ ខ្លួនចាំតែពេលនោះខ្លួនចាក់សាំងដោយដើរទៅទិញសាំង ស្រាប់តែមានមនុស្សជិះស្កុបពីពណ៌ស គប់ខ្លួន។ នៅថ្ងៃកើតហេតុគឺពុំបានឃើញមនុស្សទាំង ០៦ នោះទេ។ កើតហេតុ ០២ លើកដោយលើកទី១ ក្រោយត្រូវគេគប់ខ្លួនសន្លប់ ក្រោយមកលើកទី២ ខ្លួនសន្លប់ក្នុងផ្ទះ។ នៅថ្ងៃកើតហេតុខ្លួន ដើរទៅទិញសាំងដោយមិត្តភក្តិខ្លួនមានគ្នា ០៨ នាក់ហើយគ្នាខ្លួនបានឃើញក្រុមផ្សេងជិះមក ដោយឃើញក្រុមរបស់ឈ្មោះ រក្សា ចុះមកកាប់យក១តែម្តង។ ខ្លួនត្រូវរបួសដោយសារត្រូវដុំថ្មប៉ុណ្ណោះ ដោយត្រូវ ០១ ដុំថ្ម សន្លប់តែម្តង ហើយទើបឃើញ ០១ ក្រុមផ្សេងទៀតជិះមក។ ខ្លួនសុំដកពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] វិសាល ជាបងប្អូនជីដូនមួយ។ នៅថ្ងៃកើតហេតុពុំបានឃើញឈ្មោះ [redacted] វិសាល នោះទេ។

**៣. ការស្តាប់ចម្លើយសាក្សី**

៣.១. ឈ្មោះ [redacted] ផល្លី នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅវេលាម៉ោងប្រហែល ១៩ និង ៣០ នាទី មានអ្នកស្រុកដែលនៅជិតផ្ទះរបស់ខ្លួន បានមកទិញបារី និងទឹកផ្លែឈើនៅផ្ទះខ្លួនហើយបានអង្គុយនៅលើតុ។ លុះដល់ម៉ោង ២០ និង ៣០ នាទី មានជនមិនស្គាល់ឈ្មោះម្នាក់ទៀតបានជិះម៉ូតូម៉ាកស្កុបពី ពណ៌ខ្មៅ ០៩ គ្រឿង ពីជើងមកទិញអេសផ្ទះរបស់ខ្លួន ហើយក៏បានអង្គុយលេងនៅលើតុជាមួយមនុស្ស ១២ នាក់ ទៀតអង្គុយចុចទូរស័ព្ទតែម្នាក់ឯង។ លុះដល់ម៉ោងប្រហែល ១៩ និង ៣០ នាទី មានជនមិនស្គាល់អត្តសញ្ញាណបានជិះម៉ូតូពីត្បូងប្រហែល ១១ ម៉ូតូ ក្នុង ០១ ម៉ូតូ ជិះគ្នា ០២ នាក់ បានឈប់ម៉ូតូនៅមុខផ្ទះខ្លួនបានលើកកាំបិត និងដាវ ពេល



Scanned with CamScanner

នោះអ្នកទាំងបួននាក់ បានឃើញក៏រត់លើផ្ទះល់ ខាងជើងជាប់ផ្ទះ ខ្លួនទៅទិសខាងកើត បន្ទាប់មកជនមិនស្គាល់មុខបានជិះម៉ូតូចំនួន ២ គ្រឿង ដេញអ្នកទាំងបួន។ បន្ទាប់មកខ្លួនបានបិទទ្វារចូលផ្ទះទៅ។

៣.២. ឈ្មោះ [redacted] ស៊ាងលីម នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅម៉ោងប្រហែល ២១ និង ៣៥ នាទី មានជនមិនស្គាល់ឈ្មោះបានរត់ពីត្បូងចូលផ្ទះខ្លួន ឱ្យជួយគេផង ព្រោះមានគេ ដេញកាប់ និងយកដុំថ្មគប់ទៅលើរូបគេ។ បន្ទាប់មកមានម៉ូតូចំនួន ៣ គ្រឿង បានជិះទៅជិះមកនៅបរិវេនមុខផ្ទះ របស់ខ្លួន ហើយពួកគេស្រែកថា "អាចុយម្រាយ" ឯងចេញមកកុំពួននៅផ្ទះរបស់គេ ដោយបងប្រុសរបស់ខ្លួន ឃើញពួកគេជិះម៉ូតូជិះចុះជិះឡើងនៅមុខផ្ទះ និងស្រែកដេរជនមិនស្គាល់ឈ្មោះដែលរត់ចូលផ្ទះ ឱ្យខ្លួនជួយ ខ្លាច ពួកគេចូលផ្ទះខ្លួន បងប្រុសរបស់ខ្លួន

**សិទ្ធិនិយាយស្តីរបស់គាតី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ជនជាប់ចោទឈ្មោះ [redacted] វិសាល សំណូមពរបន្ធូរបន្ថយទោស។

២. ជនជាប់ចោទឈ្មោះ [redacted] សាន់ សំណូមពរបន្ធូរបន្ថយទោស។

៣. ជនជាប់ចោទឈ្មោះ [redacted] ហុងស្រេង សំណូមពរតុលាការសម្រេចឱ្យរួចផុតបទចោទ។

៤. ជនជាប់ចោទឈ្មោះ [redacted] គុយហេង សំណូមពរបន្ធូរបន្ថយទោស។

៥. ជនជាប់ចោទឈ្មោះ [redacted] រក្សា សំណូមពរតុលាការបន្ធូរបន្ថយទោស។

៦. ជនជាប់ចោទឈ្មោះ [redacted] គីមហុង សំណូមពរតុលាការបន្ធូរបន្ថយទោស។

**ខ. សេចក្តីសន្និដ្ឋាន៖**

**១. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖**

ក្រោយពីបានស្តាប់ការសួរដេញដោលលើជនជាប់ចោទទាំង ៦ នាក់ បានទទួលស្គាល់កំហុសរបស់ខ្លួន ហេតុនេះស្នើសុំប្រធានក្រុមប្រឹក្សាពិចារណាតាមច្បាប់។

**២. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

**២.១. លោក** [redacted] ក្រោយពេលបានស្តាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា បើពិនិត្យពាក្យបណ្តឹងពុំមានធាតុផ្សំតាមច្បាប់ ពុំមានយុត្តិធម៌ចំពោះកូនក្តី ហើយពុំមានឈ្មោះកូនក្តីខ្ញុំបាទ មានអាយុតិចជាអនីតិជន មានចំណេះដឹងទាប ហេតុការណ៍ពុំមានទំនាស់ផ្ទាល់ខ្លួន។ សាក្សីដែលបំភ្លឺពុំមានសាក្សីណាចង្អុលនិងដាក់បន្ទុកព្យសនកម្មពុំមាន។ កូនក្តីខ្ញុំពុំមែនជាម្ចាស់ម៉ូតូ ឬមានអាវុធបង្ហាញថា ពុំមានឆន្ទះបញ្ចប់សកម្មភាពពុំមានធាតុផ្សំអត្តនោម័តចូលរួម ពុំមានបទល្មើស ហិង្សាដោយចេតនា តាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយហេតុថាដើមបណ្តឹងរដ្ឋប្បវេណីដកពាក្យ ហេតុនេះសម្រេចឱ្យកូនក្តីខ្ញុំបាទរួចផុតបទចោទ។

**២.២. លោក** [redacted] ក្រោយពេលបានស្តាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា ពុំមានភស្តុតាងដាក់បន្ទុកក្រៅពីវិមតិសង្ស័យ ហេតុនេះកូនក្តីខ្ញុំបាទត្រូវទទួលបានការការពារវិធានផ្ទៃក្នុងមាត្រា ៣៥១ នៃ



Scanned with CamScanner

ក្រមនីតិវិធីព្រហ្មទណ្ឌ ស្នើសុំវិធានទាំងឡាយដែលទាក់ទងនឹងមាត្រា ៣៩ មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ មាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ មាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌដែលទាក់ទងនឹងការព្យួរទោស។

**២.៣.** លោក [redacted] [redacted] ក្រោយពេលបានស្ដាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា អង្គហេតុទំនាស់កើតហេតុ ២ ក្រុម ក្រុមទី១ បានប្រព្រឹត្តគប់ត្រូវដើមបណ្ដឹងរដ្ឋប្បវេណី ដើមបណ្ដឹងរដ្ឋប្បវេណីទទួលស្គាល់ អង្គហេតុទី២ គឺផ្ដើលកើតឡើងដោយសារសង្គម ដោយដើមបណ្ដឹងរដ្ឋប្បវេណីពុំមានចេតនាប្ដឹងទេ ជនជាប់ចោទ ៦ នាក់នេះ ពុំបានចូលទៅកាប់ ឬគប់ទេ ដោយក្មេងៗតាមគ្នាបង្កឱ្យមានបទល្មើស។ ក្រោយកើតហេតុពុំមានស្គាល់អ្នកណាឡើយ។ អនីតិជនបានជាប់ពន្ធនាគាររយៈពេល ៦ ខែ ក្រោយសាកសួរដើមបណ្ដឹងរដ្ឋប្បវេណីស្គាល់តែ ១ នាក់។ ឯកត្តកម្មនៃទោស គឺពុំបានប្រព្រឹត្តស្នើសុំផ្ដល់យុត្តិធម៌ ដល់កូនក្ដីដោយសារកូនក្ដីពុំបានប្រព្រឹត្ត។

**២.៤.** លោកស្រី [redacted] ក្រោយពេលបានស្ដាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា ឈ្មោះ [redacted] ហុងស្រេង ពុំបានប្រព្រឹត្តដោយសារកូនក្ដីខ្ញុំពុំបានប្រើហិង្សា តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ឡើយ ចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពុំមានចម្លើយណាមួយដាក់បន្ទុកឡើយ។ កូនក្ដីខ្ញុំបាទបានសារភាពថា កាន់ដុំថ្ម ដែលអង្គហេតុកើតឡើង ២ លើក។ កូនក្ដីខ្ញុំកាន់ដុំថ្ម បានកាន់ដុំថ្មតែមិនទាន់បានគប់។ ជនរងគ្រោះថា បានគប់លើកទី១ តែមិនមែនគប់លើកទី២ ធាតុផ្សំនៃមាត្រា ២១៧ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌពុំមានប៉ុនប៉ងនោះទេ ហេតុនេះពុំមានពាក់ព័ន្ធ សូមតុលាការពិចារណា។ កូនក្ដីខ្ញុំបានឆ្លើយពេលទៅពុំមានកាន់ តែមកវិញ គឺគេផ្ញើរ ហេតុនេះពុំមានព្យសនកម្ម។ ទី២ ទាក់ទងវិធានការទទួលខុសត្រូវមាត្រា ៣៨ មាត្រា ៣៩ ការទទួលខុសត្រូវរបស់ជនជាប់ចោទ ចាប់ពី ១៨ ឡើង ហេតុនេះស្ថិតក្នុងអនីតិជនពុំមានម៉ូតូជិះមកវិញឡើយ។ នាពេលអង្គសវនាការ ជនរងគ្រោះដកពាក្យបណ្ដឹង ក៏ពុំបានដឹងថា ដាក់ពាក្យបណ្ដឹងដោយសារមិនចេះអក្សរ។ ជនរងគ្រោះ និងជនជាប់ចោទពុំមានគំនុំនោះទេ។ ហេតុនេះស្នើសុំពិចារណា និងសម្រេចឱ្យកូនក្ដីរួចផុតបទចោទ។

**២.៥.** លោក [redacted] ក្រោយពេលបានស្ដាប់កិច្ចពិភាក្សាដេញដោលរួចមកឃើញថា កូនក្ដីឈ្មោះ [redacted] គុយហេង បានសារភាពកំហុសទាំងស្រុងថា ពិតជាបានចូលរួមសកម្មភាពតែពុំមានព្យសនកម្ម កូនក្ដីខ្ញុំសារភាពថា បានចូលរួម តែពុំបានបង្កព្យសនកម្ម ជនរងគ្រោះបានរងគ្រោះ ហើយខ្ញុំបាទបានមានការ កែប្រែលុតដំ ឬចូលរួមតាមវិន័យរបស់ពន្ធនាគារ។ ឈ្មោះ [redacted] គុយហេង ជាអនីតិជន ហេតុនេះស្នើសុំពិចារណា និងបន្ធូរបន្ថយទោសដើម្បីបន្តការសិក្សាវិញ តាមមាត្រា ១៦០ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

**២.៦.** លោកស្រី [redacted] ខ្ញុំឯកភាពការសន្និដ្ឋានរបស់សហភាតា ឈ្មោះ [redacted] រក្សា និងឈ្មោះ [redacted] គីមហុង ឃើញថាកូនក្ដីខ្ញុំសហការណ៍ជាមួយមន្ត្រីនគរបាលយុត្តិធម៌ ហើយការជាប់ឃុំ ការដាក់ទណ្ឌកម្ម និងកែប្រែខ្លួន។ ចំពោះអំពើដែលកូនក្ដីនាងខ្ញុំប្រព្រឹត្តពុំមានព្យសនកម្ម។ ជនរងគ្រោះដកពាក្យបណ្ដឹង ហើយពុំមានធាតុផ្សំចោទប្រកាន់ សំណូមពរក្រុមប្រឹក្សាជំនុំជម្រះសម្រេចលើកបទចោទ។



Scanned with CamScanner

*- ក្រោយពីបាន ស្តាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

*- ក្រោយពីបាន ស្តាប់សិទ្ធិនិយាយចុងក្រោយរបស់ភាគី បន្ទាប់ពីបិទកិច្ចពិភាក្សាដេញដោល*

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តី**

សាលាដំបូងខេត្តកណ្តាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **២២០៧ អ.ក** ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ (១) ឈ្មោះ [redacted] វិសាល ភេទប្រុស កើតឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ (២) ឈ្មោះ [redacted] សាន់ ភេទប្រុស កើតថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៨ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៣) ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៤) ឈ្មោះ [redacted] គុយហេង ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៣ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៥) ឈ្មោះ [redacted] វក្សា ហៅ ដី ភេទប្រុស កើតថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ ៦ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៦) ឈ្មោះ [redacted] ឈាន ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា **២១៨ នៃក្រមព្រហ្មទណ្ឌ។** និង (៨) ឈ្មោះ [redacted] **គីមហុង** ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

**ខ. អំពីដែនកំណត់នៃការប្តឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើ អង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] ហុងស្រេង ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] វក្សា ឈ្មោះ [redacted] ឈាន ឈ្មោះ [redacted] គីមហុង៕

**គ. អំពី ពិរុទ្ធភាព**

១. តាមចម្លើយជនរងគ្រោះ ចម្លើយជនជាប់ចោទគ្រប់ដំណាក់កាល និងនៅក្នុងកិច្ចពិភាក្សាដេញដោល រួមទាំងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងវត្ថុតាងផ្សេងទៀតបង្ហាញថា អង្គហេតុដែលបានប្តឹងមកតុលាការពិតជាកើតមានឡើងប្រាកដមែន។ តុលាការយល់

ឃើញថា ករណីដែលអង្គហេតុដែលប្ដឹងមកតុលាការត្រូវបានទទួលស្គាល់ តុលាការនឹងបន្តផ្ទៀងផ្ទាត់ និងវាយតម្លៃរវាងបទល្មើស ដែលត្រូវបានចោទប្រកាន់។

២. តាមសំអាងហេតុចំណុចទី១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] ហុងស្រេង ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] រក្សា ឈ្មោះ [redacted] ឈាន ឈ្មោះ [redacted] គីមហុង ពុំបានបំពេញធាតុផ្សំនៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ដើម្បីធ្វើការចោទប្រកាន់អំពើហិង្សាទៅលើអ្នកដទៃទាមទារឱ្យមានជនរងគ្រោះដែលទទួលរងរបួសដោយសារតែអំពើហិង្សារបស់ជនជាប់ចោទ ប៉ុន្តែក្នុងរឿងក្តីនេះ ពុំមានជនរងគ្រោះណាមួយបានរងរបួស ហើយក៏ពុំមានការប៉ុនប៉ងចំពោះបទចោទប្រកាន់នេះដែរ ប៉ុន្តែគឺជាសកម្មភាពដែលជនជាប់ចោទទាំងអស់ បានធ្វើសកម្មភាពគំរាមកំហែងថា នឹងសម្លាប់ទៅជនរងគ្រោះទៅវិញ ព្រោះសកម្មភាពនេះ ជនជាប់ចោទបានប្រដាប់ដោយអាវុធ ធ្វើសកម្មភាពដេញកាប់គំរាមកំហែងជនរងគ្រោះ ដែលនេះជាធាតុផ្សំនៃបទ **គំរាមកំហែងថា នឹងសម្លាប់** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

៣. តាមសំអាងហេតុចំណុចទី១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] គីមហុង បានបំពេញធាតុផ្សំនៃបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្ត នៅចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ ថាកខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៕

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្តតាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

១. តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើ បង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] ហុងស្រេង ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] រក្សា ឈ្មោះ [redacted] ឈាន ឈ្មោះ [redacted] គីមហុង បានបំពេញផ្សំនៃបទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្តនៅចំណុចភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ មានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វិសាល ឈ្មោះ [redacted]

សាន់ ឈ្មោះ [redacted]ហុងស្រេង ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] រក្សា ឈ្មោះ [redacted] ឈាន ឈ្មោះ [redacted] គីមហុង មានពិរុទ្ធភាពពីបទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្តនៅចំណុចភូមិព្រែកបី ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

២. តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើ បង្ហាញថា ជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] គីមហុង បានបំពេញធាតុផ្សំនៃបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិព្រែកបី ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] គីមហុង មានពិរុទ្ធភាពពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិព្រែកបី ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ។

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាន និងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស និងដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] វិសាល ឈ្មោះ[redacted] សាន់ ឈ្មោះ[redacted]ហុងស្រេង ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] រក្សា ឈ្មោះ [redacted] ឈាន ឈ្មោះ [redacted] គីមហុង គឺជាអនីតិជន ហេតុនេះ ទោសដែលត្រូវយកមកអនុវត្តចំពោះអនីតិជន ដែលមានក្នុងមាត្រា ១៦០ និងមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត។ តុលាការ សម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារតាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌដោយសម្រេចប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទ (១) ឈ្មោះ [redacted] វិសាល ភេទប្រុស កើតឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ (២) ឈ្មោះ [redacted] សាន់ ភេទប្រុស កើតថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៨ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៣) ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៤)



Scanned with CamScanner

ឈ្មោះ [redacted] គុយហេង ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៣ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៥) ឈ្មោះ [redacted] រក្សា ហៅ ឌី ភេទប្រុស កើតថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ ៦ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៦) ឈ្មោះ [redacted] ឈាន ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ក្នុងម្នាក់ៗចំនួន ៧ (ប្រាំពីរ) ខែ បទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្ត នៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើស ព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ ព្រោះទណ្ឌកម្មខាងលើ នេះ តុលាការពិនិត្យឃើញថា ស្ថិតនៅក្នុងកម្រិតខ្ពស់ធៀបនឹងកម្រិតអតិបរមានៃទោសដាក់ពន្ធនាគារចំនួន ១ (មួយ) ឆ្នាំ សម្រាប់បទចោទប្រកាន់នេះ ហើយវាមានភាពធួនល្មមទៅនឹងអំពើរបស់ជនជាប់ចោទ ដែលបានធ្វើ ឱ្យប៉ះពាល់ជនរងគ្រោះ និងបានធ្វើឱ្យសង្គមមានភាពច្របូកច្របល់នៅពេលដែលមានបទល្មើសកើតឡើង។ ទណ្ឌកម្មនៃទោសនេះ នឹងជួយអប់រំកែប្រែជនជាប់ចោទឱ្យក្លាយជាមនុស្សល្អក្នុងសង្គម ដើម្បីក្លាយជាកោសិកា ដ៏ល្អរបស់សង្គមកម្ពុជា។ (៧) ឈ្មោះ [redacted] គីមហុង ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្ត សញ្ញាណខាងលើ ចំនួន **៧ (ប្រាំពីរ)** ខែ បទ **គំរាមកំហែងថានឹងសម្លាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារ ធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះទណ្ឌកម្មខាងលើនេះ តុលាការពិនិត្យ ឃើញថា ស្ថិតនៅក្នុងកម្រិតខ្ពស់ធៀបនឹងកម្រិតអតិបរមានៃទោសដាក់ពន្ធនាគារចំនួន ១ (មួយ) ឆ្នាំ សម្រាប់ បទចោទប្រកាន់នេះ ហើយវាមានភាពធួនល្មមទៅនឹងអំពើរបស់ជនជាប់ចោទ ដែលបានធ្វើឱ្យប៉ះពាល់ជនរង គ្រោះ និងបានធ្វើឱ្យសង្គមមានភាពច្របូកច្របល់នៅពេលដែលមានបទល្មើសកើតឡើង។ ទណ្ឌកម្មនៃទោស នេះ នឹងជួយអប់រំកែប្រែជនជាប់ចោទឱ្យក្លាយជាមនុស្សល្អក្នុងសង្គម ដើម្បីក្លាយជាកោសិកាដ៏ល្អរបស់សង្គម កម្ពុជា។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល, ថ្ងៃទី 08 ខែ ០៣ ឆ្នាំ ២០២
ក្រឡាបញ្ជី

**ឆ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។

## សេចក្ដីសម្រេច

**ក. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទ៖**

១. (១) ឈ្មោះ [redacted] វិសាល ភេទប្រុស កើតឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ [redacted] (២) ឈ្មោះ [redacted] សាន់ ភេទប្រុស កើតថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៨ ថ្ងៃ) ដូចមានអត្ត សញ្ញាណខាងលើ (៣) ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៤) ឈ្មោះ [redacted] គុយហេង ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៣ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៥) ឈ្មោះ [redacted] រក្សា ហៅ ឌី ភេទប្រុស កើតថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ ៦ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ (៦) ឈ្មោះ



Scanned with CamScanner

[redacted]ឈាន ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ និង (៧) ឈ្មោះ [redacted] គីមហុង ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **គំរាមកំហែងថានឹងសម្លាប់** បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបទចោទប្រកាន់លើជនជាប់ចោទពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ទៅជាបទ **គំរាមកំហែងថានឹងសម្លាប់** បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣។

២. ឈ្មោះ [redacted] គីមហុង ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ បទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្តាល ថ្ងៃទី០៩ ខែ ០១ ឆ្នាំ២០
ក្រឡាបញ្ជី

**ខ. ផ្តន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] វិសាល ភេទប្រុស កើតឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៧ (ប្រាំពីរ) ខែ បទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្ត [redacted] កណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

២. ឈ្មោះ [redacted] សាន់ ភេទប្រុស កើតថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៨ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៧ (ប្រាំពីរ) ខែ បទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

៣. ឈ្មោះ [redacted] ហុងស្រេង ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៧ (ប្រាំពីរ) ខែ បទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

៤. ឈ្មោះ [redacted] គុយហេង ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ (អាយុ ១៧ ឆ្នាំ ៥ ខែ ៣ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៧ (ប្រាំពីរ) ខែ បទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្តនៅចំណុច ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

៥. ឈ្មោះ [redacted] រក្សា ហៅ អី ភេទប្រុស កើតថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៨ (អាយុ ១៥ ឆ្នាំ ៦ ខែ ១ ថ្ងៃ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៧ (ប្រាំពីរ) ខែ បទ **គំរាមកំហែងថានឹងសម្លាប់** ប្រព្រឹត្តនៅចំណុច ភូមិ



Scanned with CamScanner

ព្រៃកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

៦. ឈ្មោះ [redacted] ឈាន ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៧ (ប្រាំពីរ) ខែ បទ គំរាមកំហែងថានឹងសម្លាប់ ប្រព្រឹត្តនៅចំណុច ភូមិព្រៃកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។

៧. ឈ្មោះ [redacted] គីមហុង ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៧ (ប្រាំពីរ) ខែ បទ គំរាមកំហែងថានឹងសម្លាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិព្រៃកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៦០ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៕

*សំណុំរឿងព្រហ្មទណ្ឌនេះជំនុំជម្រះជាអសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សៃហាល ឈ្មោះ [redacted] សាន់ ឈ្មោះ [redacted] ហុងស្រេង ឈ្មោះ [redacted] គុយហេង ឈ្មោះ [redacted] ក្សា ឈ្មោះ [redacted] គីមហុង និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឈាន។*

*សាលក្រមព្រហ្មទណ្ឌនេះប្រកាសជាអសាធារណៈនៅថ្ងៃ ព្រហស្បតិ៍ ១ រោច ខែពិសាខ ឆ្នាំរោង ឆស័ក [redacted] ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ១០ ព្រឹក នៅសាលសវនាការលេខ ៥។*

*ភាគីដែលមានបំណងធ្វើបណ្តឹងទាស់ ឬបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះត្រូវធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍នេះ តាមការកំណត់របស់ច្បាប់។*

ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

| ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ព្រហស្បតិ៍ ១ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤

| បានឃើញ | |
|---|---|
| ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ក្រឡាបញ្ជីសវនាការ |
| [redacted] | [redacted] |



Scanned with CamScanner